# ជំហានទី៥

## សារភាពកំហុសដែលយើងបានធ្វើចំពោះព្រះ ចំពោះខ្លួនឯង និងអ្នកដទៃ



ជំហានទាំង១២ទាមទារឲ្យយើងធ្វើអ្វីដែលខុសពីនិស្ស័យនៃលោកីយ៍។ និស្ស័យចូលចិត្តទាញយើងឲ្យកសាងអាត្មា*(ខ្លួនឯងជាធំ ជាអ្វីតែផ្នែកខាងក្រៅដែលធ្វើដើម្បីទទួលបាននូវការកោតសរសើរពីអ្នកដទៃ ចង់បានមុខមាត់ជាដើម)*។ ជំហានទី៥នេះជាជំហានដែលពិបាក និងទាមទារឲ្យយើងដក**អាត្មា**នេះចេញ។ ពីព្រោះយើងបានកសាង**អាត្មា**ឡើងឲ្យក្លាយជាប៉មមួយយ៉ាងខ្ពស់ ហើយបន្ទាប់មកយើងត្រូវដកជញ្ជាំងនៃប៉មនេះចេញបន្តិចម្តងៗវិញ។ ជំហានទី៥នេះជាជំហានដែលពិបាកជាងគេ ប៉ុន្តែមានប្រសិទ្ធិភាពខ្ពស់ក្នុងការកសាងភាពប្រក្រតីឲ្យមានស្ថេរភាព។

តាមបទពិសោទន៍អេ.អេបានប្រាប់យើងថា យើងមិនអាចរស់នៅបានតែម្នាក់ឯងដោយស្ពាយសំពាយនៃចរិតលក្ខណៈអាក្រក់ និងបញ្ហាផ្លូវចិត្តរហូតទេ។ ចរិតលក្ខណៈអាក្រក់ជាអ្នកបំពុល និងបង្កឲ្យយើងជួបសេចក្តីវិនាសអន្តរាយ។ តាមពិតយើងជាមនុស្សរស់ក្នុងបញ្ហាស្រាប់ ប៉ុន្តែចរិតលក្ខណៈអាក្រក់បានបង្កបញ្ហាតូចៗដែលយើងមាននោះឲ្យទៅជាបញ្ហាធំ។ យើងបានឆ្លងកាត់ជំហានទី៤រួចមកហើយ វាជាជំហានដែលដឹកនាំយើងព្រមពិនិត្យមើលពីចរិតលក្ខណៈអាក្រក់របស់ខ្លួន។ តាមបទពិសោធន៍នៃខ្សែជីវិតនឹងរំលឹកយើងឲ្យឃើញពីគំនិតខុសឆ្គងដែលជាសកម្មភាពមួយនាំយើងឲ្យធ្វើបាបចំពោះខ្លួនឯង និងអ្នកដទៃ ក្រោយពីបានធ្វើជំហានទី៤រួចហើយ យើងមានអារម្មណ៍ថាលែងចង់រស់នៅឆ្ងាយពីអ្នកដទៃទៀតហើយ។ បើសិនជាយើងរស់នៅឆ្ងាយពីអ្នកដទៃ វាងាយស្រួលឲ្យយើងអាចលាក់ចរិតលក្ខណៈអាក្រក់របស់ខ្លួនបាន ហេតុដូច្នេះហើយអេ.អេ លើកទឹកចិត្តឲ្យយើងរកមនុស្សម្នាក់ដែលយើងទុកចិត្ត ហើយអាចចែករំលែករឿងរ៉ាវជីវិតជាមួយគ្នាបាន។ ចំពោះអ្នកដែលចង់ផ្តាច់ស្រាមែនគេត្រូវតែរកអ្នកដែលគេទុកចិត្តហើយសារភាពរឿងរ៉ាវជីវិតនិងអាថ៌កំបាំងក្នុងចិត្តដោយស្មោះត្រង់។ មានអេអេជាច្រើននាក់ដែលបានគេចវេស និងរំលងជំហានទី៥នេះ ពីព្រោះអេអេថ្មីចូលចិត្តតែផ្លូវកាត់ (ខ្លាចក្នុងការធ្វើជំហានទី៥)។ ពេលគេចង់គេចវេស គេមិនចង់និយាយឲ្យត្រង់ៗទេ គេនិយាយតែពីការផឹក ឬនិយាយបង្វែងដាន ឧ. គេចូលចិត្តនិយាយថា "ពេលខ្ញុំផឹកខ្ញុំជាមនុស្សអាក្រក់មែន" ពាក្យនេះវាទូទៅពេកអត់បញ្ជាក់ឲ្យជាក់លាក់ថាអាក្រក់នោះពីអ្វី ពេលខ្លះគេប្រាប់បន្ថែមតែពីរឿងរ៉ាវនិងស្ថានភាពផ្នែកខាងក្រៅក្នុងការផឹកស្រវឹងរបស់ខ្លួន អ្វីដែលគេនិយាយទាំងនេះសុទ្ធតែអ្នកផ្សេងដឹងរួចហើយ វាមិនមែនជារឿងអាថ៌កំបាំងអ្វីទេ។ ហេតុតែយើងលាក់មិននិយាយប្រាប់អ្នកផ្សេងពីអ្វីដែលបានរំខានខាងផ្លូវចិត្ត និងការឈឺចិត្ត ឬភាពអាម៉ាសដែលនាំឲ្យយើងរត់ទៅផឹកដើម្បីបំភ្លេចអ្វីៗទាំងអស់នេះទេ អ៊ីចឹងមានតែអោបវាទុកយកទៅកប់ជាមួយប៉ុណ្ណោះ។

អេអេប្រាប់ថា អ្នកដែលមានអាកប្បកិរិយាខ្ជីខ្ជាចំពោះជំហានទី៥នេះ មិនមែនជារឿងល្អនោះទេ ពីព្រោះការខ្ជីខ្ជានេះបានក្លាយជាឧបសគ្គដល់ស្ថេរភាពនៃការផ្តាច់ស្រា។ ឧបសគ្គធំជាងគេនៅ អេ.អេ គឺសមាជិកម្នាក់នោះមិនសារភាពប្រាប់ពីភាពអាក្រក់ដែលជាស្រមោលក្នុងដួងចិត្តខ្លួន ហើយគេអាចនឹងត្រឡប់ទៅរកការផឹកស្រាឡើងវិញ។ អ្នកខ្លះក៏ត្រឡប់ទៅរកអេ.អេវិញ ពីព្រោះតែគេមិនអាចរក្សាការផ្តាច់ស្រាបាន គេមានតែដើរជាមួយអេ.អេហូតដល់ព្រមធ្វើជំហានទី៥នេះដោយស្មោះអស់ពីចិត្ត។ សមាជិកអេអេបញ្ជាក់ប្រាប់គេថា អ្នកនឹងរងទុកជាមួយនឹងភាពតប់ប្រមល់ ភាពតានតឹង ភាពភ័យខ្លាច ការបារម្ភ ការមួម៉ៅ កំហឹង និងការអន់ចិត្តជាមិនខានបើសិនជាអ្នកមិនព្រមធ្វើជំហានទី៥ឲ្យស្មោះចេញពីចិត្តទេនោះ។ ពេលខ្លះគេចេះចាប់កំហុសពួកម៉ាកគេ ព្រោះតែចង់បិទបាំងចរិតលក្ខណៈអាក្រក់របស់ខ្លួន និងដើម្បីកំសាន្តចិត្តខ្លួនឯងដែរ។ បើសិនជាយើងមើលឃើញ

តែពីកំហុសអ្នកដទៃ និងបេះតែបន្ទោសគេនោះវាមិនអាចជួយយើងឲ្យទទួលបាននូវភាពធូរស្បើយទេ យើងត្រូវតែសារភាពកំហុសខ្លួនដើម្បីឲ្យធូរស្រាលក្នុងចិត្ត។ ទម្លាប់នៃកាសារភាពកំហុស ឬលន់តួបាបខ្លួនចំពោះគ្នាទៅវិញទៅមកនេះមានតាំងតែពីយូរយាណាស់មកហើយ ព្រោះនេះជាទម្លាប់របស់សាសនាធំៗ ដែលយើងអាចឃើញបាន។ ទម្លាប់នេះបង្ហាញពីចរិតលក្ខណៈភាពជាមនុស្សដែលពេញដោយព្រះវិញ្ញាណ(គេអាចឃើញបានតាមរយៈព្រះពុទ្ធ ឬព្រះគ្រិស្ត ដែលទ្រង់បានបង្ហាញពីឫទ្ធានុភាពនៃព្រះ)។ បច្ចុប្បន្ននេះ ទម្លាប់ក្នុងការលន់តួបាបមិនមែនតែជាទម្លាប់ខាងសាសនាទេ ប៉ុន្តែគេអាចឃើញទម្លាប់នេះត្រូវបានបណ្ឌិតខាងផ្នែកចិត្តសាស្ត្រ និងអ្នកពិគ្រោះយោបល់យកមកប្រើដើម្បីជួយដល់អ្នកជំងឺរបស់ខ្លួនឲ្យទទួលបាននូវភាពធូរស្រាល និងជួយអភិវឌ្ឍន៍ផ្នែកស្មារតីដើម្បីឲ្យគេអាចឃើញពីចរិតលក្ខណៈអាក្រក់ដែលមាននៅក្នុងផ្លូវចិត្តរបស់ខ្លួនដែរ។ ចំណែកក្រុម អេ.អេ វិញបានប្រើទម្លាប់នេះយ៉ាងពិសេសជាងសាសនា និងវេជ្ជបណ្ឌិត បើអេ.អេមិនយកទម្លាប់នេះមកប្រើឲ្យអស់ពីកំលាំងកាយចិត្តទេ ប្រក្រតីភាពដែលពួកយើងមានមិនស្ថិតស្ថេរបានយូអង្វែងទេ។ តាមពិតព្រះគុណនៃព្រះមិនអាចលុបចោលនូវគំនិតអាក្រក់ និងការប្រព្រឹត្តដែលបង្កវិនាសកម្មដល់អ្នកដទៃឲ្យអស់តែម្តងនោះទេ លុះត្រាតែយើងសុខចិត្តទាំងស្រុងក្នុងការលន់តួបាបខ្លួនដោយមិនលាក់លាមចំពោះអ្នកដទៃ។

តើជំហានទី៥មានអត្ថប្រយោជន៍អ្វីខ្លះ?

ទីមួយ ទុក្ខលំបាកអ្នកញៀនស្រាគឺជាភាពឯកោ (ការមិនស៊ីចង្វាក់គ្នានឹងគេក្នុងការចូលរួមសកម្មភាពផ្សេងក្នុងសង្គមហើយរាប់ខ្លួនឯងជាមនុស្សឯកោ កំសត់ គ្មានអ្នកយល់ចិត្តជាដើម)។ ។ សូម្បីតែមុនយើងផឹកខ្លាំង និងមុនគេកាត់យើងចោលចេញពីសង្គម យើងមានអារម្មណ៍ថាយើងមិនស៊ីចង្វាក់ជាមួយមនុស្សគ្រប់គ្នា។ មុនចូលអេ.អេ គេរាប់អ្នកញៀនស្រាមាន២ប្រភេទ មួយជាអ្នកអៀនគេចពីសកម្មភាពផ្សេងៗក្នុងសង្គម មួយទៀតជាអ្នកដែលចូលចិត្តភាពអ៊ូអរសប្បាយ ដើម្បីទទួលបាននូវការរាប់អាន ប៉ុន្តែវាមិនដូចអ្វីដែលគាត់ចង់បាននោះទេ។ ២ចំណុចខាងលើនេះប្រៀបដូចជារនាំងមួយដែលបាំងយើង មិនឲ្យមើលឃើញនិងមិនអាចឆ្លងកាត់ទៅរកភាពស៊ីចង្វាក់នឹងគេបាន។ ជួនកាលយើងដូចជាអ្នកសម្តែងម្នាក់នៅលើឆាកដែលកំពុងតែភ្លេចប៉ារ៉ូលមិនដឹងសំដែងយ៉ាងម៉េច (មិនដឹងចុះចូលជាមួយគេយ៉ាងម៉េច)។ មូលហេតុមួយគឺយើងចូលចិត្តផឹកស្រា ពេលមានស្រាយើងមានប៉ារ៉ូលចេញមកយ៉ាងស្រួលក្នុងការចូលរួមសកម្មភាពជាមួយនឹងគេ។ នៅថ្ងៃណាមួយពេលស្រាអស់ប្រសិទ្ធិភាពក្នុងការជួយយើងឲ្យស៊ីចង្វាក់នឹងគេហើយ យើងនៅតែមានអារម្មណ៍កំសត់ឯកាឡើងវិញ។

នៅទីបំផុតយើងរកបានក្រុមមួយដែលយើងចង់បាន គឺក្រុមអេ.អេដែលអាចឲ្យយើងទទួលបាននូវអារម្មណ៍កក់ក្តៅ និងស្កប់ចិត្ត ពីព្រោះយើងចូលចំណោមនឹងគេចុះ ។ ពេលចូលអេ.អេបានមិនយូរប៉ុន្មានយើងនឹងមានម្មណ៍ថាភាពឯកោ និងការកំសត់របស់យើងបានរសាយបាត់អស់ហើយ។ ប៉ុន្តែបន្តិចក្រោយមកទៀតអារម្មណ៍ឯកោការកំសត់ក៏ត្រឡប់មកវិញដោយសារតែយើងអត់ទាន់មានភាពស្មោះត្រង់ចំពោះខ្លួនឯង ស្តីពីវិវាទ និងចរិតលក្ខណៈអាក្រក់ ដោយយើងអត់ទាន់បានបើកចិត្តប្រាប់ការពិតដល់អ្នកដែលយើងទុកចិត្ត តែបើយើងមានកាស្មោះត្រង់ចំពោះខ្លួនឯង និងបើកចិត្តប្រាប់ដល់អ្នដ៏ទៃ វាជាបទពិសោធន៍ដែលអាចឲ្យយើងឃើញពីឫទ្ធានុភាពនៃព្រះ និងភាពចុះសំរុងគ្នាជាមួយនឹងសមាជិកអេ.អេ។ ជំហានទី៥គឺជាដំណោះស្រាយដ៏ល្អឥតខ្ចោះមួយ។

ក្រោយពីធ្វើជំហានទី៥ចប់ គេជឿថាព្រះនឹងអភ័យទោសរាល់កំហុសរបស់គេ មិនថាកំហុសនោះតូច ឬធំទេ។ ហើយនៅពេលគេធ្វើជំហានទី៥ជាមួយអ្នកផ្តល់ឱវាទ គេចាប់ផ្តើមមានសមត្ថភាពក្នុងការអភ័យទោស ដល់អស់អ្នកដែលធ្វើឲ្យគេឈឺចាប់ខ្លាំង។ តាមជំហានទីបួនអាចសជួយឲ្យយើងចេះអភ័យទោសដល់គេ តែបន្ទាប់ពីធ្វើជំហានទី៥ជាមួយអ្នកផ្តល់ឱវាទហើយ យើងនឹងទទួលកាអភ័យទោសផង និងចេះអត់ទោសឲ្យគេផងដែរ។

មានផលមួយទៀតដែលទទួលបានពីការធ្វើជំហានទី៥នេះ គឺឲ្យយើងចេះបន្ទាបខ្លួន។ក្រោយពីមានដំណើរការល្អជាមួយអេ.អេហើយយើងនឹងចេះវាស់វែងមើលឃើញច្បាស់ថាយើងជាអ្នកណាកាលពីមុន ហើយខុសគ្នាឥឡូវយ៉ាងម៉េច ហើយយើងនឹងក្លាយជាអ្នកណានាពេលអនាគត។ ទី១ អេ.អេដែលចេះបន្ទាបខ្លួន គឺជាអេ.អេដែលចេះសារភាពកំហុសរបស់ខ្លួន។ ទី២ការមើលឃើញពីចរិតលក្ខណៈអាក្រក់វាល្អហើយ តែត្រូវមានសកម្មភាពផងដែរក្នុងការកែប្រែចរិតលក្ខណៈអាក្រក់នោះ។

នៅជំហានទី៤ គឺជាជំហានដែលតំរូវឲ្យយើងដកឃ្លាយកពេលដើម្បីសម្លឹងមើលពីខ្លួនឯង។ ហើយយើងទាំងអស់គ្នាសុទ្ធតែដឹងថា យើងខ្វះភាពស្មោះត្រង់ ខ្វះភាពអត់ធ្មត់ និងមានភាពរើសអើងនឹងអ្នកផ្សេង។ ពេលធ្វើជំហានទី៤និងទី៥ យើងនឹងមានអារម្មណ៍តូចចិត្តអាណិតខ្លួនឯង ហើយមានការស្រមើស្រមៃចង់បានអំណាចនិងមានកេរ្តិ៍ឈ្មោះ។ ម្យ៉ាងទៀតការឆ្លងកាត់ជំហានទី៤និងទី៥នេះ ធ្វើឲ្យយើងខ្មាសខ្លួនឯង និងខ្មាសអ្នកដែលយើងចែករំលែករឿងជាមួយ។ ការខ្មាសអៀន នេះមិនមែនមានន័យថាយើងចេះបន្ទាបខ្លួន និងអាចផ្លាស់ប្តូរចរិតលក្ខណៈអាក្រក់បានឡើយ។ ការសម្លឹងមើលពីខ្លួនឯង គឺគ្រាន់តែជាការមើលឃើញ តែយើងត្រូវតែមានការអនុវត្តន៍ឲ្យចេញជាសកម្មភាពក្នុងការកែប្រែខ្លួនដែរ។ បើសិនយើងគ្រាន់តែមានបំណងនោះមិនមែនមានន័យថាមានសកម្មភាពក្នុងការកែប្រែខ្លួនទេ។

បើយើងបានឆ្លងកាត់ជំហានទី៥ហើយ មានន័យថាយើងសំរេចកិច្ចកាបានយ៉ាងល្អក្នុងការបង្ហាញពីសេចក្តីស្មោះត្រង់យ៉ាងពិតប្រាកដចំពោះខ្លួនឯង។ អ្វីដែលយើងរៀនបានពីជំហានទី៥ គឺធ្វើឲ្យយើងយល់កាន់តែច្បាស់ពីការកុហករបស់ខ្លួនដែលជាដើមហេតុបង្កបញ្ហាជាច្រើនដល់ខ្លួន។ ប៉ុន្តែក្នុងការឆ្លងកាត់ជំហានទី៥នេះមិនមានដំណើរការយ៉ាងរលូនទេ ពេលខ្លះយើងនឹងឆ្ងល់ថាតើយើងនៅតែបោកបន្លំខ្លួនឯង ឬឈប់កុហកខ្លួនឯងទៀតហើយ។ ពេលខ្លះយើងសួរខ្លួនឯងថាតើយើងនៅមានចរិតលក្ខណៈអាក្រក់ដែលយើងមិនបានសារភាពចំពោះខ្លួនឯង និងប្រាប់អ្នកផ្សេងដែរឬទេ ពេលខ្លះយើងឆ្ងល់ថា (តើ)យើងខ្លាចក្នុងការសារភាពពីចរិតលក្ខណៈអាក្រក់របស់ខ្លួន ឬឈប់ខ្លាចហើយ។ ដោយសារតែយើងនៅមានការភ័យខ្លាច ការអាណិតអាសូរខ្លួនឯង និងការឈឺចាប់ដែលជាហេតុមិនអាចឲ្យយើងវាយតំលៃដោយខ្លួនឯងឲ្យត្រូវ១០០%បានទេ យើងមានហេតុផល៣ផ្សេងទៀតនៅខាងក្រោមនេះ៖

១. ពេលយើងមើលឃើញពីខ្លួនឯង ហើយមានអារម្មណ៍ថាខ្មាសខ្លួនឯង និងមានវិប្បដិសារីនោះមានន័យថាយើងបានវាយតំលៃពីចរិតលក្ខណៈអាក្រក់របស់ខ្លួនធ្ងន់ធ្ងរពេក លើសពីការពិត ដែលនាំឲ្យយើងបន្ទោសខ្លួនឯងហួត។

២. គំនុំ និងការស្អប់អ្នកផ្សេង ប្រៀបដូចជាផ្ទៃងបាំងដួងចិត្តយើងមិនឲ្យមើលឃើញពីចរិតលក្ខណៈអាក្រក់ខ្លួន នៅពេលយើងធ្វើជំហានទី៤និងទី៥ វាអាចជួយរំសាយផ្ទៃងចេញខ្លះ មិនទាំងអស់ទេ។
៣. យើងមិនអាចវាយតំលៃដោយខ្លួនឯងឲ្យច្បាស់១០០%ទេ ពីព្រោះការធ្វើដំណើររបស់យើងជាមួយនឹង អេ.អេ មិនទាន់ដល់ដំណាក់កាលមួយដែលអាចឲ្យយើងឃើញពីចរិតលក្ខណៈអាក្រក់
និងអារម្មណ៍អាក្រក់របស់ខ្លួនបានទាំងអស់នោះទេ។

ជំហានទី៤ជាវិធីមួយល្អមែនទែនដែលនាំយើងសញ្ជឹងគិតនិងធ្វើបញ្ជីពីចរិតលក្ខណៈអាក្រក់តែម្នាក់ឯង។ តាមការធ្វើជំហានទី៤នេះល្អហើយ តែបើយើងចង់ឃើញឲ្យច្បាស់ពីចរិតលក្ខណៈអាក្រក់នោះ យើងត្រូវរកអ្នកផ្សេងឲ្យជួយដើម្បីឲ្យយើងអាចសារភាពការពិតពីខ្លួនឯងបាន។ យើងត្រូវការព្រះ និងអ្នកចាស់ទុំ អេ.អេឲ្យជួយ។ បើយើងចង់មានភាពស្មោះត្រង់ចំពោះខ្លួនឯង និងអ្នកដទៃ និងចេះបន្ទាបខ្លួន យើងត្រូវស្មោះត្រង់ក្នុងការប្រាប់រឿងយើងផ្ទាល់ដោយមិនលាក់លាម ហើយព្រមទទួលយកការណែនាំពីអ្នកផ្តល់ឱវាទអេ.អេ ដើម្បីកែប្រែគំនិតខុសឆ្គងរបស់ខ្លួន។ មានអ្នកខ្លះគេសួរថា ហេតុអ្វីត្រូវតែរកអ្នកផ្សេងដើម្បីចែកចាយរឿងជាមួយ? និងហេតុអ្វីយើងមិនអាចចែកចាយរឿងតែជាមួយនឹងព្រះទៅបានហើយ?។ បើគេមានទម្លាប់ចែកចាយតែជាមួយព្រះ យូៗទៅគេនឹងលែងខ្លាចព្រះ។ តែបើគេចង់ឲ្យជំហានទី៥មានប្រសិទ្ធិភាព គឺគេត្រូវតែរកម្នាក់ដើម្បីអាចចែកចាយរឿងជាមួយបាន។ បើយើងមិនប្រាប់រឿងអាថ៌កំបាំងក្នុងចិត្តជាមួយអ្នកផ្សេងទេ ហើយយើងបែរជានិយាយថាយើងទទួលបានការកែប្រែ ហើយនេះជាការអះអាងខ្យល់។ ក្នុងជំហានទី៥នេះនាំឲ្យយើងហ៊ានបើកចិត្តនិយាយការពិតជាមួយអ្នកដទៃក៏ដូចជាយើងចាប់ផ្តើមឈប់កុហកខ្លួនឯងទៀតហើយ។

ពីបញ្ហាទី២ បើយើងធ្វើការវាយតំលៃតែម្នាក់ឯង វាងាយស្រួលឲ្យយើងវែកញែករកហេតុផលពីចរិតលក្ខណៈអាក្រក់ ហើយយើងនឹងមានភាពលំអៀងទៅរកការល្អជាជាងការអាក្រក់ពីខ្លួនឯង។ នៅពេលណាយើងមានការសន្ទនាជាមួយអ្នកផ្សេង យើងទទួលបាននូវដំបូន្មាននិងមតិដើម្បីស្តាបនាត្រូវ មិនឲ្យយើងច្រលំពីព្រោះគេបានផ្តល់ជាឱវាទត្រង់ៗដោយផ្ទាល់ ហើយនៅពេលយើងអត់ច្បាស់យើងអាចសួបាន។ បើយើងចង់យល់ពីបញ្ហាផ្លូវចិត្តឲ្យច្បាស់ យើងត្រូវតែរកគ្នាជួយ បើមិនអ៊ីចឹងទេវាអាចបណ្តាលឲ្យមានមហន្តរាយកើតឡើងជាក់ជាមិនខាន។ ជាពិសេសយើងត្រូវការការណែនាំ និងប្រាជ្ញាពីចាស់ទុំអេ.អេ។ មនុស្សដែលចង់អភិវឌ្ឍភាពចាស់ទុំទាំងផ្លូវចិត្ត និងព្រលឹងវិញ្ញាណ គឺគេជាមនុស្សដែលស្វែងរកការណែនាំពីពួកម៉ាក និងអ្នកផ្តល់ឱវាទរបស់គេ។ មួយវិញទៀត ពេលណាគេធ្វើអ្វីមួយហើយរាប់ថាការនោះត្រឹមត្រូវតាមដំបូន្មានរបស់ព្រះ ប៉ុន្តែពេលខ្លះអាចធ្វើឲ្យគេយល់ច្រឡំបាន ពីព្រោះអ្វីដែលគេធ្វើ គឺគេគិតតែម្នាក់ឯង ជួនកាលខុសជួនកាលត្រូវ ដូច្នេះជាការល្អគេត្រូវសួរអ្នកផ្តល់ឱវាទជាមុនសិនមុននឹងធ្វើអ្វីមួយ។ អ្នកចំណូលថ្មី អេ.អេ តោងដឹងថាការណែនាំពីអ្នកដទៃមិនមែនសុទ្ធតែត្រូវទាំងអស់នោះដែរ តែបើយើងរកជំនួយពីព្រះក៏អាចឲ្យយើងយល់ច្រឡំ ពីព្រោះយើងមិនសូវមានបទពិសោធន៍ក្នុងការស្តាប់លឺពីព្រះ និងទំនាក់ទំនងល្អជាមួយនឹងព្រះទេ អ៊ីចឹងយើងមានតែរកអ្នកផ្តល់ឱវាទឲ្យជួយ ពីព្រោះពួកគេមានបទពិសោធន៍ស្រាប់ យើងមិនត្រូវពឹងលើខ្លួនតែម្នាក់ឯងបានទេ។

បញ្ហាមួយទៀត យើងត្រូវរកមនុស្សម្នាក់ដែលអាចឲ្យយើងចែកចាយរឿងយើងបាន ប៉ុន្តែយើងត្រូវប្រយ័ត្នក្នុងការរកមនុស្សដែលយើងទុកចិត្ត។

យើងជ្រើសរើសមនុស្សម្នាក់ដែលយើងទុកចិត្តអាចស្តាប់រឿងអាថ៌កំបាំងរបស់យើងបាន ជាពិសេសគេមានបទពិសោធន៍ជាមួយអេ.អេ និងទទួលប្រក្រតីភាពយូរឆ្នាំហើយដែរ អ្វីដែលល្អជាងនេះគឺគេមានប្រវត្តិដូចយើងដែរ។ នៅពេលយើងដើរដល់ជំហានទី៤និងទី៥ យើងត្រូវតែមានអ្នកផ្តល់ឱវាទហើយ។ អ្នកចំណូលថ្មីមកដល់អេ.អេ គេត្រូវរកអ្នកផ្តល់ឱវាទម្នាក់ដែលអាចទុកចិត្តបានដើម្បីជួយគេក្នុងការឆ្លងកាត់កម្មវិធីអេ.អេ។ សំរាប់ជំហានទី៥ សមាជិកអេ.អេត្រូវតែដើរជាមួយអ្នកផ្តល់ឱវាទពីព្រោះយើងស្គាល់គ្នាស្រាប់ហើយ។ ហើយសមាជិកអេ.អេមានសេរីភាពអាចជ្រើសរើសអ្នកផ្តល់ឱវាទបាន អាចជា វេជ្ជបណ្ឌិត លោកសង្ឃ គ្រូគង្វាល ឬសង្ឃកាតូលិកក៏បាន។

សំខាន់ជាងគេក្នុងជំហានទី៥នេះមាន២ចំណុចៈ

១.ការសុខចិត្តចែកចាយរឿងផ្ទាល់ខ្លួនឲ្យអស់ពីចិត្តគ្មានការលាក់លាម។

២.ត្រូវមានការទុកចិត្តចំពោះអ្នកដែលយើងបានជ្រើសរើសដើម្បីអាចចែកចាយរឿងផ្ទាល់ខ្លួនបាន។

ម្យ៉ាងទៀតការជ្រើសរើសមនុស្សម្នាក់ដែលយើងទុកចិត្ត ហើយអាចឲ្យយើងសុខចិត្តប្រាប់រឿងដោយស្មោះត្រង់ជាមួយគេបាន។ ជំហានទី៥ ជាជំហានដែលអាចឲ្យយើងចាប់ផ្តើមក្លាហាន និងមានចេតនាក្នុងការប្រាប់រឿងរ៉ាវផ្ទាល់ខ្លួនជាមួយអ្នកផ្សេង។ បើយើងចង់សំរេចកិច្ចការឲ្យបានល្អក្នុងជំហានទី៥នេះ យើងត្រូវចែកចាយឲ្យអស់ដល់អ្នកដែលស៊ីចង្វាក់គ្នានឹងយើង និងបង្ហាញការទុកចិត្តចំពោះគ្នា នោះគេនឹងរំភើបចិត្តក្នុងការជួយយើង។ យើងនឹងមានអារម្មណ៍ភ្ញាក់ផ្អើល ធូរស្រាល និងទទួលបាននូវភាពកក់ក្តៅ នៅពេលស្តាប់លឺពីប្រវត្តិរបស់ពួកគេដែរ ពីព្រោះពួកគេបានចែកចាយពីបទពិសោធន៍ និងចរិតលក្ខណៈអាក្រក់របស់ខ្លួន ខណៈដែលយើងកំពុងចែកចាយរឿងផ្ទាល់របស់យើងដែរនោះ។ ពេលនោះភាពតានតឹង ការតប់ប្រមល់ ការខ្វល់ព្រួយក្នុងចិត្តដែលយើងទុកយូរឆ្នាំហើយនឹងរសាយអស់នៅពេលណាយើងបានចែកចាយជាមួយអ្នកដែលយើងទុកចិត្ត។

ប្រសិនបើយើងចែកចាយដោយអត់លាក់លាមទេ យើងនឹងធូរស្បើយបន្តិចម្តងៗ នៅពេលយើងបន្តប្រាប់ដល់អ្នកដែលយើងបានជ្រើសរើស។ ការឈឺចាប់ក្នុងផ្លូវចិត្តនឹងបានជាសះស្បើយ នោះយើងនឹងចាប់ផ្តើមភ្លក់ពីសន្តិភាពក្នុងផ្លូវចិត្តយើងជាលើកដំបូង។ អេ.អេជាច្រើននាក់ប្រាប់យើងថា នៅពេលយើងឆ្លងកាត់ជំហានទី៥ចប់ នោះយើងនឹងទទួលអារម្មណ៍ថាមានព្រះគង់នៅជាមួយយើង។ អេ.អេដែលមានជំនឿស្រាប់ គេកាន់តែរឹងមាំផ្នែកស្មារតីនិងជំនឿរបស់គេកាន់តែខ្លាំងជាងមុន។ ការធ្វើជំហានទី៥នេះ យើងនឹងមានអារម្មណ៍ថា យើងមានភាពស្និទ្ធស្នាលជាមួយនឹងព្រះ និងអ្នកដទៃ។ ដ្បិតតាមរយៈការចែកចាយដោយស្មោះត្រង់អាចជាបន្ទុកមួយដែលនាំឲ្យយើងបន្ទោសខ្លួនឯងរហូត ប៉ុន្តែការនេះអាចនាំយើងឲ្យចាកចេញពីជីវិតឯកោ និងការរស់នៅមិនស៊ីចង្វាក់នឹងគេបាន ហើយក៏អាចនាំយើងឲ្យចូលក្នុងការសំរាកមួយដើម្បីត្រៀមខ្លួនឆ្លងកាត់ជំហានទី៦ដល់ទី១២ ដែលជាតំណាក់កាលធ្វើឲ្យជីវិតទទួលភាពប្រក្រតី និងជីវិតមានន័យ។